ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:២៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា៣ ថ្មី(ពីរ)នៃអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣ ថ្មីនៃអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣នៃអនុក្រឹត្យស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា និងមាត្រា៧នៃអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១២ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រាមួយ .-**

មាត្រា៣ ថ្មី(ពីរ)នៃអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣ ថ្មីនៃអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣នៃអនុក្រឹត្យស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា និងមាត្រា៧នៃអនុក្រឹត្យលេខ៩៤

អនុក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា ត្រូវបានធ្វើការកែសម្រួល ដូចតទៅ៖

**មាត្រា៣ ._ ថ្មី(ចឺ)**

សមាសភាពនៃលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា មានដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | អគ្គលេខាធិការ |
| ៨- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| ១៨- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| ១៩- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| ២០- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| ២១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប | សមាជិក |
| ២២- តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១រូប | សមាជិក |
| ២៣- តំណាងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន ១រូប | សមាជិក។ |

ក្រៅពីសមាសភាពខាងលើនេះ លេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា អាចមានសមាសភាពបន្ថែមពីក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់នៃការងារ។

**មាត្រា៧ ._ ថ្មី**

ប្រធានលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា អាចអញ្ជើញរដ្ឋមន្ត្រីឬប្រធានស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំឬធ្វើរបាយការណ៍ក្នុងករណីចាំបាច់ ដើម្បីពិភាក្សានិងដោះស្រាយរាល់បញ្ហាទាក់ទងនឹងកិច្ចការអាស៊ាន។

លេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនឱ្យបានទៀងទាត់ ជាពិសេស នៅមុនរាល់កិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដើម្បីសម្របសម្រួលថ្នាក់ជាតិនូវកិច្ចការអាស៊ាន។

ប្រធានលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា អាចធ្វើការកោះប្រជុំលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា ឬកោះប្រជុំតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍អាស៊ានទាំងបី ដើម្បីសម្របសម្រួលថ្នាក់ជាតិនិងត្រៀមរៀបចំសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាននិងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗឱ្យបានល្អប្រសើរ។

**មាត្រាពីរ ._**

អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣ ថ្មី នៃអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣នៃអនុក្រឹត្យស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១១ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ